ISSUE #093

លោកដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត
ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក

Free COPY

ចម្បាំងគ្រប់សម័យកាល

ផ្នែកទី ២៖ ការការពារពីការបោកបញ្ឆោត

នៅក្នុងការកែសម្រួលថ្មីនៃសៀវភៅ ការការពារពីការបោកបញ្ឆោត ដែលឥឡូវនេះត្រូវបានបោះពុម្ពឡើងវិញក្រោមចំណងជើង ចម្បាំងគ្រប់សម័យកាល របស់លោក ដេរេក ព្រីនស៍ បានព្រមានអំពីគ្រោះថ្នាក់ដ៏ធំបំផុតដែលគ្រីស្ទបរិស័ទនឹងប្រឈមមុខនៅគ្រាចុងក្រោយបង្អស់។

នៅក្នុងផ្នែកទីពីរក្នុងចំណោមផ្នែកទាំងបីនៃសៀវភៅ ចម្បាំងគ្រប់សម័យកាល យើងនឹងសិក្សាបន្ថែមអំពីយុទ្ធសាស្ត្រ និងល្បិចកលរបស់សាតាំង ដើម្បីឲ្យយើងអាចស្គាល់វា ទប់ទល់នឹងវា និងយកឈ្នះលើវាបាន។

ការធ្លាក់ចុះ

មនុស្សភាគច្រើនយើងនឹងយល់ស្របថា វិញ្ញាណ ព្រលឹង និងរូបកាយ បង្កើតជាបុគ្គលិកលក្ខណៈពេញលេញរបស់មនុស្ស។ ក្នុង ១ថែស្សាឡូនិច 5:23 បានចែងថា៖

ហើយឲ្យទាំងព្រលឹង នឹងវិញ្ញាណ ហើយរូបកាយ ទាំងមូលបានបំរុងទុកឥតសៅហ្មង ដរាបដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ទ្រង់យាងមក ។

ព្រលឹង ដែលរួមមានឆន្ទៈ អារម្មណ៍ និងបញ្ញា ប្រហែលជាផ្នែកមួយនៃបុគ្គលិកលក្ខណៈមនុស្សដែលពិបាកយល់បំផុត។ វាជាអត្តសញ្ញាណពិសេសរបស់មនុស្សម្នាក់ៗ ជាផ្នែកដែលកំណត់ថា «ខ្ញុំនឹងធ្វើ» ឬ «ខ្ញុំមិនធ្វើទេ»។ នៅពេលមនុស្សចុះចូលតាមការទាមទាររបស់ព្រលឹងខ្លួន ជាជាងត្រូវបានដឹកនាំដោយព្រះវិញ្ញាណរបស់ព្រះ នោះពួកគេកំពុងញែកខ្លួនចេញពីព្រះ ហើយបើកទ្វារឲ្យការបោកបញ្ឆោតចូលមក។

បទគម្ពីរមួយក្នុងគម្ពីរយ៉ាកុប ផ្តល់ឲ្យយើងនូវរូបភាពអំពីទំនាក់ទំនងរវាងវិញ្ញាណ ព្រលឹង និងរូបកាយ។ យ៉ាកុប ៣:១៥ មានពាក្យខ្លី ប៉ុន្តែមានអត្ថន័យជ្រាលជ្រៅថា៖ *«ប្រាជ្ញាយ៉ាងនោះមិនមែនពីស្ថានលើទេ គឺជារបស់ផងលោកីយនេះ ហើយក៏ខាងសាច់ឈាម នឹងខាងអារក្សវិញទេតើ»* ។ ខនេះបង្ហាញពីជំហាននៃការធ្លាក់ចុះរបស់ប្រាជ្ញា ជាការធ្លាក់ចុះ ដែលអនុញ្ញាតឲ្យពួកអារក្ស ជ្រៀតចូលក្នុងកិច្ចការរបស់ព្រះ ក្នុងជីវិតមនុស្ស និងក្នុងពួកជំនុំរបស់ព្រះ។

ការរស់នៅតាមបែបលោកិយ អាចមើលទៅហាក់ដូចជាគ្មានគ្រោះថ្នាក់អ្វីឡើយ។ ប៉ុន្តែមិនយូរប៉ុន្មាន ការព្រងើយកន្តើយនឹងចាប់ផ្តើមចាក់ឫស ហើយទាញមនុស្សម្នាក់ឲ្យធ្លាក់ចូលទៅក្នុងអាណាចក្រនៃព្រលឹង ហើយប្រហែលជាបន្តធ្លាក់ចុះទៀត ទៅក្នុងអាណាចក្រនៃអារក្សផងដែរ។

សម្រាប់ធនធានបន្ថែម សូមចូលទៅកាន់ **www.derekprince.com/km-kh**

នាំឲ្យមានអាកប្បកិរិយាមិនសមរម្យ ដែលគ្មានមូលដ្ឋានក្នុងព្រះគម្ពីរ ដូចជាការលេងសើចហួសហេតុ ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់។ ដូចអ្វីដែលលោក ឆាលី ហ្វីនី បានបញ្ចេញមតិថា៖ *«ព្រះជាម្ចាស់មិនប្រើអ្នកកំប្លែងម្នាក់ ដើម្បីពិនិត្យចិត្តមនុស្សទេ»* ។

កិច្ចការមួយរបស់ព្រះវិញ្ញាណបរិសុទ្ធ គឺការធ្វើឲ្យមនុស្សដឹងអំពើបាបរបស់ខ្លួន។ ទីណាដែលខ្វះខាតការនេះ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធក៏ទំនងជាខ្វះខាតផងដែរ។

ការគេចចេញពីអន្ទាក់របស់សាតាំង

ស្ថានភាពរបស់មនុស្សជាតិនឹងមិនប្រសើរឡើងទេ។ ក្នុង ២ធីម៉ូថេ 3:2–4 លោកប៉ុល បានព្រមានពីអ្វីដែលមនុស្សនឹងជួបប្រទះនៅគ្រាចុងក្រោយនេះ។ គាត់បានរៀបរាប់នូវគុណវិបត្តិខាងសីលធម៌ចំនួនដប់ប្រាំបីយ៉ាង ដែលនឹងកើតមានយ៉ាងទូលំទូលាយ៖

ដ្បិតនៅគ្រានោះ មនុស្សនឹងស្រឡាញ់តែខ្លួនឯង ទាំងស្រឡាញ់ប្រាក់ អួតអាងគយរ មានឫកខ្ពស់ ប្រមាថមើលងាយ មិនស្តាប់បង្គាប់ឪពុកម្តាយ រមិលគុណ មានចិត្តមិនបរិសុទ្ធ មិនស្រឡាញ់តាមធម្មតាមនុស្ស គ្មានសេចក្តីអធ្យោគ និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្តសាហាវ មិនចូលចិត្តនឹងការល្អ ក្បត់គេ ឥតបើគិតមានចិត្តធំ ហើយចូលចិត្តនឹងល្បែងលេងជាជាងព្រះ។

យើងសង្កេតឃើញថា បញ្ជីនេះចាប់ផ្តើម និងបញ្ចប់ដោយសេចក្តីស្រឡាញ់ដែលមិនត្រឹមត្រូវ គឺការស្រឡាញ់ខ្លួនឯង ស្រឡាញ់ប្រាក់ និងចូលចិត្តល្បែងលេង។ ភាពខាងព្រលឹង ឬការស្រឡាញ់ខ្លួនឯង បើកទ្វារឲ្យអំពើអាក្រក់ចូលមក។ នៅក្នុង ខទី5 បានបញ្ចប់ថា៖ *«គេមានឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ ប៉ុន្តែ មិនព្រមទទួលស្គាល់ព្រះចេស្តា ដែលមកដោយការគោរពប្រតិបត្តិនោះទេ ចូរបែរពីពួកមនុស្សយ៉ាងនោះចេញ»* ។

ទោះបីជាពួកគេមានសម្បកក្រៅនៃសេចក្តីគោរពប្រតិបត្តិដល់ព្រះ ហើយប្រហែលជាប្រកាសថាខ្លួនជាគ្រីស្ទបរិស័ទក៏ដោយ ក៏មនុស្សដែលត្រូវបានពិពណ៌នានៅទីនេះ នៅតែប្រព្រឹត្តតាមការស្រឡាញ់ខ្លួនឯង និងអំពើអាក្រក់ទាំងឡាយដែលការស្រឡាញ់ខ្លួនឯងបើកទ្វារឲ្យចូលមក។

សាតាំងមានសេចក្តីរីករាយយ៉ាងខ្លាំងចំពោះមនុស្សដែលស្រឡាញ់ និងលើកតម្កើងខ្លួនឯង ពីព្រោះវាគឺជាអ្នកដែលបានបង្កើតគំរូនៃអាកប្បកិរិយាបែបនេះមុនគេ។ សូមមើលនៅក្នុង (អេសាយ 14:12–15)។ វានាំមនុស្សឲ្យវង្វេងដោយលើកទឹកចិត្តឲ្យពួកគេស្រឡាញ់អ្វីក៏ដោយ ដូចជាមាសប្រាក់ ការកម្សាន្ត អំណាច ឬខ្លួនឯង លើសជាងការស្រឡាញ់ព្រះ។ ការស្រឡាញ់ដែលដាក់ខុសកន្លែង គឺជាការបង្ខូចនូវអ្វីដែលព្រះបានបង្កើតមកឲ្យល្អ។ ហើយនៅពេលដែលសេចក្តីស្រឡាញ់ត្រូវបានបង្ខូច វាអាចធ្វើឲ្យយើងក្លាយជាអ្នកងាយរងនូវការបោកបញ្ឆោតពីសាតាំង។ សាតាំងតែងតែយកអ្វីដែលល្អ និងបរិសុទ្ធ មកបង្វែរឲ្យក្លាយជាឧបករណ៍ដែលនាំទៅរកការបោកបញ្ឆោត និងការបំផ្លាញខ្លួនយើងវិញ។

ព្រះអម្ចាស់នឹងជួយយើង

ឥឡូវនេះ ដោយយើងបានដឹងអំពីភាពងាយរងគ្រោះរបស់យើងចំពោះការបោកបញ្ឆោត និងវិធីជាច្រើនដែលសាតាំងព្យាយាមចាប់យកចិត្តរបស់យើងហើយ នោះចូរយើងងាកមករកព្រះអម្ចាស់ ដើម្បីស្វែងរកជំនួយពីទ្រង់។ តើអ្នកនឹងចូលរួមអធិស្ឋានជាមួយខ្ញុំដែរឬទេ?

ព្រះអម្ចាស់អើយ! ទូលបង្គំចង់ឈរយ៉ាងមាំមួនក្នុងសេចក្តីពិតរបស់ព្រះអង្គ នៅក្នុងពេលវេលាដ៏សំខាន់ទាំងនេះ។ សូមទ្រង់ជួយទូលបង្គំឲ្យរក្សាចិត្ត និងគំនិតរបស់ទូលបង្គំឲ្យផ្តោតលើទ្រង់ជានិច្ច។ ទូលបង្គំមិនចង់ធ្លាក់ចូលក្នុងដំណើរនៃការធ្លាក់ចុះ «ខាងលោកីយ ខាងព្រលឹង និងខាងអារក្ស» នោះឡើយ។ ព្រះអម្ចាស់អើយ សូមទ្រង់រក្សាភ្នែករបស់ទូលបង្គំឲ្យសម្លឹងមើលទៅទ្រង់ជានិច្ច។ ដោយមានជំនួយពីទ្រង់ ទូលបង្គំនឹងបម្រើទ្រង់ដោយសេចក្តីស្មោះត្រង់ សេចក្តីពិត និងកម្លាំងដែលមកពីទ្រង់។ អាម៉ែន!

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សេចក្តីបង្រៀនជាលិខិតរបស់លោកដេរេក ព្រីនស៍ អាចទាញយកដោយឥតគិតថ្លៃពីគេហទំព័ររបស់យើង www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា
Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh

បីជំហាននៃការធ្លាក់ចុះ

១. ខាងលោកីយ (Earthly)

តើការក្លាយជាមនុស្សខាងលោកិយមានន័យដូចម្តេច? តាមទស្សនៈគ្រីស្ទបរិស័ទ មនុស្សខាងលោកិយ ផ្តោតតែទៅលើជីវិតនៅលើផែនដីនេះប៉ុណ្ណោះ ពួកគេមិនគិតអំពីអ្វីដែលលើសពីនេះទេ គឺគ្មានការគិតអំពីអ្វី ដែលនៅហួសពីជីវិតបច្ចុប្បន្ននេះឡើយ។ ប្រសិនបើមនុស្សខាងលោកិយម្នាក់ជា គ្រីស្ទបរិស័ទ គាត់រំពឹងថាព្រះនឹងប្រទានពរដែលទាក់ទងតែជាមួយជីវិតនេះប៉ុណ្ណោះ ដូចជា ទ្រព្យសម្បត្តិ ការប្រោសឲ្យជា អំណាច ភាពជោគជ័យ និងការស្វែងរកផ្សេងៗដែលបំពេញបំណងរបស់ព្រលឹង។ ដើម្បីយល់កាន់តែច្បាស់អំពីមនុស្សខាងលោកិយ វាមានប្រយោជន៍ក្នុងការពិចារណា អំពីមនុស្សដែលមិនមែនជាមនុស្សខាងលោកិយ។ លោកអ័ប្រាហាំ គឺជាគំរូមួយ៖

ដោយសារសេចក្តីជំនឿ នោះលោកបានស្នាក់នៅក្នុងស្រុក ដែលទ្រង់សន្យាឲ្យ ដូចជានៅប្រទេសដទៃ ក៏នៅតែក្នុងត្រសាល ជាមួយនឹងអ៊ីសាក ហើយនឹងយ៉ាកុប ជាអ្នកគ្រងសេចក្តីសន្យាដដែល ទុកជាមរដកជាមួយគ្នា ពីព្រោះលោករង់ចាំក្រុង១ ដែលមានប្រសជញ្ជាំង ដែលព្រះទ្រង់ជាអ្នកគូរ ហើយជាជាងសង់។

(ហេព្រើរ 11:9–10)

គំរូទីពីរនៃមនុស្សដែលមិនខាងលោកិយ គឺលោកម៉ូសេ ដែលត្រូវបានពិពណ៌នានៅក្នុងគម្ពីរហេព្រើរ 11:27 ថា៖

ដោយសារសេចក្តីជំនឿ នោះលោកក៏ចេញពីស្រុកអេស៊ីព្ទទៅ ឥតកោតខ្លាចដល់សេចក្តីកំហឹងនៃស្តេចឡើយ ដ្បិតលោកបានកាន់យ៉ាងខ្ជាប់ខ្ជួន ហាក់ដូចជាឃើញព្រះដ៏មើលមិនឃើញដែរ។

ម៉ូសេអាចស៊ូទ្រាំបាន ពីព្រោះគាត់មើលហួសពីការលំបាកបច្ចុប្បន្នទៅកាន់សេចក្តីសម្រេចដ៏ពេញលេញពិតប្រាកដនៅពេលអនាគត។

នៅក្នុង ១កូរិនថូស 15:19 លោកប៉ុលបានសរសេរថា *«បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនា លើសជាងមនុស្សទាំងអស់ទៅទៀត។»* ប្រសិនបើគោលបំណងនៃជំនឿគ្រីស្ទបរិស័ទរបស់យើង គឺដើម្បីទទួលបានពរជ័យ សម្រាប់តែជីវិតនៅលើផែនដីនេះប៉ុណ្ណោះ នោះយើងពិតជាគួរឲ្យអាណិតមែន។ មនុស្សជាច្រើនបានភ្លេចថា យើងគ្រាន់តែជាអ្នកដំណើរឆ្លងកាត់ពិភពលោកនេះប៉ុណ្ណោះ។ ជាលទ្ធផល គំនិត និងមហិច្ឆតារបស់ពួកគេបាត់បង់ទិសដៅត្រឹមត្រូវហើយពួកគេក្លាយជាមនុស្សខាងលោកិយ។

២. ខាងព្រលឹង (Soulish)

ខាងព្រលឹង គឺជាកម្រិតមួយដែលទាបជាងខាងលោកិយ។ ដូចដែលបានពន្យល់រួចមកហើយ ព្រលឹងជាគឺជា «អត្មា» ឬខ្លួនឯង។ មនុស្សខាងព្រលឹង គឺជាមនុស្សដែលផ្តោតលើខ្លួនឯងជាចម្បង ហើយខ្ចល់ ខ្វាយតែអំពីប្រយោជន៍របស់ខ្លួនប៉ុណ្ណោះ។ ខណៈដែលមនុស្សខាងវិញ្ញាណសួរថា «តើខ្ញុំអាចលើកតម្កើងព្រះយ៉ាងដូចម្តេច?» មនុស្សខាងព្រលឹងវិញសួរថា «តើខ្ញុំនឹងទទួលបានអ្វីពីរឿងនេះ?» ពួកជំនុំសម័យបច្ចុប្បន្នជាច្រើន ពេលខ្លះផ្តោតទៅលើការបំពេញបំណងប្រាថ្នាផ្ទាល់ខ្លួនបែបនេះ ជាជាងការស្វែងរកសិរីល្អរបស់ព្រះ។

នៅក្នុង១កូរិនថូស 2:14-15 លោកប៉ុល បានសរសេរថា៖

ប៉ុន្តែ មនុស្សខាងសាច់ឈាម [ខាងព្រលឹង] គេមិនទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ ឯមនុស្សខាងវិញ្ញាណវិញ គេពិចារណាយល់គ្រប់ទាំងអស់បាន តែមិនត្រូវអ្នកណាពិចារណាខ្លួនឡើង។

មនុស្សខាងព្រលឹង មិនអាចយល់ដឹងសេចក្តីពិតខាងវិញ្ញាណបានទេ ពីព្រោះសេចក្តីពិតទាំងនោះត្រូវបានដឹងតាមរយៈ វិញ្ញាណ។ គាត់ស្តាប់ និងឆ្លើយតបតែចំពោះអ្វីដែលប៉ះពាល់ដល់អារម្មណ៍ និងបំណងប្រាថ្នារបស់ព្រលឹងប៉ុណ្ណោះ។ មនុស្សម្នាក់អាចត្រូវបានជំរុញដោយអាកប្បកិរិយាខាងព្រលឹងឲ្យថ្វាយដង្វាយមួយភាគដប់ ឬថ្វាយដង្វាយយ៉ាងច្រើនដល់ពួកជំនុំ។ ប៉ុន្តែប្រសិនបើការថ្វាយនោះកើតចេញពីការជម្រុញចិត្តមិនត្រឹមត្រូវ នោះវានឹងមិនមានតម្លៃខាងវិញ្ញាណតាមដែលគួរមាន ឡើយ។

មនុស្សដែលរស់នៅក្នុងអាណាចក្រនៃព្រលឹង ងាយត្រូវបានអូសទាញឲ្យវង្វេង ដោយមិនចាំបាច់ប្រើកម្លាំងច្រើនទេ ហើយដោយរបៀបនេះ ពួកគេបើកផ្លូវឲ្យខ្លួនឯងធ្លាក់ចូលក្នុងការបោកបញ្ឆោត។

ការការពារតែមួយគត់ គឺត្រូវរៀនបែងចែកឲ្យច្បាស់រវាងអ្វីដែលជាខាងវិញ្ញាណ និងអ្វីដែលជាខាងព្រលឹង។

៣. ខាងអារក្ស (Demonic)

មួយជំហានទៀតដែលទាបជាងខាងព្រលឹង គឺខាងអារក្ស។ គំរូនៃការធ្លាក់ចុះពីខាងលោកិយ ទៅខាងព្រលឹង ហើយបន្តទៅខាងអារក្ស ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងគម្ពីរសញ្ញាចាស់ តាមរយៈរឿងរបស់អើរ៉ុន ដែលជាសម្តេចសង្ឃរបស់អ៊ីស្រាអែល ហើយបានបង្កើតរូបព្រះ

មាសមួយ។ និក្ខមនំ 32:1-6 ពិពណ៌នាអំពីការធ្លាក់ចុះរបស់គាត់ថា៖

កាលបណ្តាជនទាំងឡាយបានឃើញថា ម៉ូសេក្រចុះមកពីលើភ្នំវិញដូច្នេះ នោះគេប្រជុំគ្នាទៅឯអើរ៉ុនជំរាបថា សូមលោកធ្វើព្រះសំរាប់យើងរាល់គ្នា ឲ្យបាននាំមុខយើងផង ដ្បិតឯម៉ូសេ ជាអ្នកដែលនាំយើងចេញពីស្រុកអេស៊ីព្ទមក នោះ យើងរាល់គ្នាមិនដឹងជាលោកមានគ្រោះថ្នាក់អ្វីទេ...។

មានចំណុចសំខាន់ៗមួយចំនួនក្នុងអត្ថបទនេះ ដែលគួរកត់សម្គាល់។ ទីមួយ ប្រជាជនបានផ្តល់កិត្តិយសដល់ម៉ូសេសម្រាប់ការរំដោះពួកគេ «ជាអ្នកដែលនាំយើងចេញពីស្រុកអេស៊ីព្ទមក» ជាជាងទទួលស្គាល់ថា ព្រះទេដែលបានរៀបចំ និងប្រទានការរំដោះនោះ។ ការផ្តោតលើមេដឹកនាំជាមនុស្ស បានប្រែក្លាយទៅជាការថ្វាយបង្គំរូបព្រះ។

បទគម្ពីរនេះ បញ្ចប់ដោយការថ្វាយបង្គំរូបព្រះផងដែរ *«ប្រជាជន... ក្រោកឡើងលេងសប្បាយ»* (ខ6)។ ការ «លេងសប្បាយ» គឺជាលក្ខណៈសំខាន់មួយនៃការថ្វាយបង្គំរូបព្រះ។ នៅពេលការថ្វាយបង្គំរបស់យើងក្លាយទៅជាការកម្សាន្ត ឬការស្វែងរកភាពសប្បាយរីករាយផ្ទាល់ខ្លួន នោះយើងបានរអិលចេញពីអាណាចក្រខាងវិញ្ញាណ ទៅកាន់អាណាចក្រខាងព្រលឹង ហើយនៅទីបំផុត ទៅកាន់អាណាចក្រខាងអារក្ស។

អ្វីជាច្រើនដែលយើងហៅថា «ការថ្វាយបង្គំ» នៅក្នុងព្រះវិហាររបស់យើង តាមពិតមិនមែនជាការថ្វាយ បង្គំឡើយ។ វាផ្តោតលើខ្លួនឯងដោយស្វែងរកថាតើយើងអាចទទួលការប្រោសឲ្យជា ព្រះពរ និងការផ្គត់ផ្គង់ផ្សេងៗពីព្រះដោយរបៀបណា។ តន្ត្រីជាច្រើននៅក្នុងកម្មវិធីថ្វាយបង្គំសព្វថ្ងៃនេះ ទាក់ទាញដល់ព្រលឹង ដោយជំរុញវាតាមរបៀបដូចគ្នានឹងតន្ត្រីលោកិយដែរ។

ការស្តារឡើងវិញនូវការកោតខ្លាចព្រះ

នៅក្នុងគម្ពីរសញ្ញាថ្មី សៀវភៅហេព្រើរបានដាស់ តឿនយើងឲ្យរក្សាការកោតខ្លាច និងការគោរពចំ ពោះព្រះ ដូចដែលព្រឹត្តិការណ៍ក្នុងគម្ពីរសញ្ញាចាស់បានបង្កើតឡើង ដូចជាការជំនុំជម្រះរបស់ព្រះលើក្រុងសូដុំ និងកូម៉ូរ៉ា។ ហេព្រើរ 12:28–29 ចែងថា៖

ដូច្នេះ ដែលទទួលនគរ១ដ៏កក្រើការញ្ជួយពុំបាន នោះត្រូវឲ្យយើងដឹងគុណ ដែលដោយសារសេចក្តីនោះ យើងនឹងបំរើព្រះបែបឲ្យទ្រង់សព្វព្រះហប្ចទ័យ ទាំងមានចិត្តគោរពប្រតិបត្តិ ហើយកោតខ្លាចដល់ទ្រង់ ដ្បិតព្រះនៃយើងរាល់គ្នា ទ្រង់ជាភ្លើងដែលឆេះបន្សុស។

គំរូមួយនៅក្នុងសញ្ញាថ្មីស្តីពីការជំនំជម្រះរបស់ព្រះជាម្ចាស់ គឺនៅពេលដែលទ្រង់បានវាយប្រហារ អាន្នាំនាស និងប្រពន្ធឈ្មោះសាភីរ៉ា ដោយសារពួកគេបានក្លែងបន្លំការថ្វាយដង្វាយរបស់ពួកគេ។ បន្ទាប់ពីហេតុការណ៍នោះ គម្ពីរបានចែងថា៖ *«រួចពួកជំនុំទាំងប៉ុន្មាន និងអស់អ្នកណាដែលឲ្យនិយាយពីការនោះ ក៏កើតមានសេចក្តីស្ងែងខ្លាចទាំងអស់គ្នា»* (កិច្ចការ 5: 11)។



សព្វថ្ងៃនេះ តើយើងឃើញការកោតខ្លាច និងការគោរពចំពោះព្រះប៉ុន្មាននៅក្នុងពួកជំនុំ? នៅប្រទេសអង់គ្លេស ក្នុងរដូវ ក្តៅមួយ ខ្ញុំបាននិយាយជាមួយមិត្តភក្តិម្នាក់ដែលជាគ្រូបម្រើព្រះ។ គាត់បាននិយាយថា៖

ខ្ញុំជួបមនុស្សជាច្រើនដែលនិយាយអំពីព្រះ ដូចជាទ្រង់គ្រាន់តែជាមនុស្សម្នាក់ដែលពួកគេបានជួបនៅក្នុងហាងស្រាប៉ុណ្ណោះ។

មនុស្សជាច្រើន ចាត់ទុកព្រះជាម្ចាស់ដូចជាមិត្តធម្មតា ឬជាមិត្តជិតស្និទ្ធម្នាក់ប៉ុណ្ណោះ។ ពិតណាស់ព្រះទ្រង់អញ្ជើញយើង ឲ្យមានការប្រកប និងការរួបរួមជាមួយទ្រង់។ ប៉ុន្តែ យើងមិនគួរបាត់បង់ញ្ញាណនៃការគោរពកោតខ្លាចចំពោះភាពបរិសុទ្ធរបស់ព្រះអង្គឡើយ។